ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ២៤ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

ក

មាតិកា

I . ឯកសារគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

០៣-៧-១៩៩៥ – អនុក្រឹត្យលេខ ៥៥ អនក្រ.បក ស្តីពីការបែងចែកខ្ទង់ចំណាយឥតគ្រោងទុក ១០៦៣

០១-៧-១៩៩៥ – អនុក្រឹត្យលេខ ៧៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៦៤

០១-៧-១៩៩៥ – អនុក្រឹត្យលេខ ៧៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៦៥

០១-៧-១៩៩៥ – អនុក្រឹត្យលេខ ៧៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៦៦

០៥-៧-១៩៩៥ – អនុក្រឹត្យលេខ ៧៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៦៨

០៥-៧-១៩៩៥ – អនុក្រឹត្យលេខ ៧៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៦៩

០៦-៧-១៩៩៥ – អនុក្រឹត្យលេខ ៨០ អនក្រ.តត ស្តីពីការលុបអនុក្រឹត្យលេខ ៣៦ អនក្រ និង អនុក្រឹត្យលេខ ១០១ អនក្រ ១០៧០

២-សេចក្តីសំរេច

០៤-៧-១៩៩៥ – សេចក្តីសំរេចលេខ ៤៧ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះសំរាប់កិច្ចសហប្រតិបត្តិការកម្ពុជា - ហុងគ្រី ១០៧១

II-ការងារបណ្តាក្រសួង

១-ឯកសាររដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

០៣-៧-១៩៩៥ – ប្រកាសលេខ ២៣៥ ប្រក.សហវ.ថ ស្តីពីការបង្វែរឥណទាន ១០៧៤

២-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

ប្រកាស

០១-៧-១៩៩៥ – ប្រកាសលេខ ៤៦១ សសរ.សកប ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រី រាជការ ១០៧៦

០១-៧-១៩៩៥ – ប្រកាសលេខ ៤៦២ សសរ.សកប ស្តីពីការបង្កើតគណៈកម្មការបច្ចេកទេសជំនួយគណៈកម្មការកណ្តាលសាងសង់ព្រះសក្យមុនីចេតិយ៍ ១០៧៧

០១-៧-១៩៩៥ – សេចក្តីសំរេចលេខ ៤៦៣ សសរ.សកប ស្តីពីការតែងតាំងមន្ត្រីរាជការ ១០៧៩

០៣-៧-១៩៩៥ – ប្រកាសលេខ ៤៦៤ ប្រក.សកប ស្តីពីការបញ្ចូលមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួង ១០៨០

៣-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

០៣-៧-១៩៩៥ – ប្រកាសលេខ ១០៤/៩៥ ពម.ប្រក ស្តីពីការបង្កើតអនុគណៈកម្មការទទួលសំភារៈទូរទស្សន៍ ១០៨១

០៦-៧-១៩៩៥ – ប្រកាសលេខ ១៤៥/៩៥ ពម ស្តីពីការអនុញ្ញាតអោយលោក ម៉ម សូណង់ដូ បើកស្ថានីយ៍វិទ្យុផ្សាយសំឡេង FM រលកអាកាស ១០៥ ១០៨២

០៧-៧-១៩៩៥ – ប្រកាសលេខ ១៤៦/៩៥ ពម.ប្រក ស្តីពីការអនុញ្ញាតអោយលោក តាំង ឃាង បើកអាជីវកម្មរោងពុម្ពឈ្មោះ«ហេង ហេង» ១០៨៣

៤-ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

០៣-៧-១៩៩៥ – ប្រកាសលេខ ១២៣ ប្រក.វវស.បុ ស្តីពីការផ្អាកការងារមួយរយៈដោយពុំទទួលបៀវត្ស ១០៨៥

០៣-៧-១៩៩៥ – ប្រកាសលេខ ១២៤ ប្រក.វវស.បុ ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការ ១០៨៦

៥-ទីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

០៥-៧-១៩៩៥ – ប្រកាសលេខ ៣៨៧ ប្រក.កសក.ចត ស្តីពីការតែងតាំងតំលើងឋានៈមន្ត្រីរាជការ ១០៨៧

៦-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

០៣-៧-១៩៩៥ – ប្រកាសលេខ ៤៦៧ ផក.ប្រក អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **ផាន់ ខ្មែរ** ជាប្រធាន បើកដំណើរការផលិតកម្មដោយប្រើម៉ាស៊ីនកំលាំង ២៤ សេះ ១០៨៩

០៣-៧-១៩៩៥ – ប្រកាសលេខ ៤៦៨ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី **សុខ ឡឹង** បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ ១០៩០

ឧស្ស

០៣-៧-១៩៩៥ – ប្រកាសលេខ ៤៦៩ ផក.ប្រក អនុញ្ញាតអោយលោក **ស្ទួន ហៀង** បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ ១០៩០

០៣-៧-១៩៩៥ – ប្រកាសលេខ ៤៧០ ផក.ប្រក អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវ ដែលមានអ្នកស្រី គីម សាន ជាប្រធាន បើកដំណើរការផលិត ដោយប្រើម៉ាស៊ីនកំលាំង ៨០ សេះ ១០៩១

០៣-៧-១៩៩៥ – ប្រកាសលេខ ៤៨១ ផក.ប្រក អនុញ្ញាតអោយលោក សុខ ហាវ ជាប្រធាន បើកដំណើរការសហគ្រាសផលិតគ្រឿងសង្ហារឹម «តូនី» ១០៩១

០៧-៧-១៩៩៥ – ប្រកាសលេខ ៤៨៦ ផក.ប្រក អនុញ្ញាតអោយលោក ឡេង ឫទ្ធី ជាប្រធាន បើកដំណើរការរោងឧស្សាហកម្មផលិតគ្រឿងសង្ហារឹម «ឫទ្ធីមិចកូ RITTHY MEXCO» ១០៩២

I- ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៥៥ អនក្រ.បក

ស្តីពីការបែងចែកខ្ទង់ចំណាយឥតគ្រោងទុក

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១.ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១០ ន.ស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែក ឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : ផ្តល់ឥណទានបន្ថែម ដោយយកចេញពីជំពូក ៤១ (ចំណាយឥតគ្រោងទុក) នៃ

ថវិការដ្ឋជូនទៅក្រសួងពាណិជ្ជកម្ម ជំពូក ៣០ ចំនួន ១០០ លានរៀល (មួយរយលានរៀលគត់) ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តអនុក្រឹត្យនេះចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
ហ៊ុន សែន

* * * *

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៧៥ អនក្រ.កត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិប្រគេន និង ជូនចំពោះព្រះសង្ឃ ១ អង្គ និង

សប្បុរសជន ៤ រូប ដែលមានសទ្ធាជ្រះថ្លាជួយកសាងព្រះវិហារវត្តព្រៃកល្ងង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល :

ក–មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ប្រគេន ជូនចំពោះ ÷

១–ព្រះតេជគុណ **ស៊ិន ឈុន** ចៅអធិការវត្តព្រៃកល្ងង ដែលបានបរិច្ចាគបច្ច័យ ចំនួន ៤០.០០០ ដុល្លារអាមេរិក ។

២–លោក គី ហេង ប្រធានក្រុមហ៊ុនសំណង ឃុំព្រែកអំពិល បានឧបត្ថម្ភប្រាក់ចំនួន ៣៦.០០០ ដុល្លារអាមេរិក ។

ខ–មេដាយស្ថាបនាជាតិថ្នាក់លេខ ២ ជូនចំពោះ លោក **ស៊ិន សម្ផស** បានឧបត្ថម្ភប្រាក់ ចំនួន ៥.២០០ ដុល្លារអាមេរិក

គ–មេដាយស្ថាបនាជាតិថ្នាក់លេខ ៣ ជូនចំពោះ ÷

១–លោក **អ៊ុំ ស៊ុនថាន់** ឧបត្ថម្ភប្រាក់ ចំនួន ២.៦០០ ដុល្លារអាមេរិក

២–លោកស្រី **អ៊ុំម គីមឆួក** ឧបត្ថម្ភប្រាក់ ចំនួន ២.៥០០ ដុល្លារអាមេរិក

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្ដាល ត្រូវអនុវត្ត អនុក្រឹត្យនេះអោយបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៧៦ អនក្រ.តត

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុវរ្ម័ន**

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់ លេខ ១ ចំពោះសមាគមខ្មែរ នៅរដ្ឋចរចាសហរដ្ឋអាមេរិក ដែលបានឧបត្ថម្ភប្រាក់ ចំនួន ១៤.៥០០ ដុល្លារអាមេរិកជួយកសាងអាគារ សិក្សា ១ ខ្នង នៅក្នុងបរិវេណ(អនុវិទ្យាល័យគគីរធំ) ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាលត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៧៧ អនក្រ.គត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន**

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់សាលាក្រុងភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់ លេខ ១ ចំពោះសប្បុរសជនចំនួន ០២ រូប ដែលបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួនជួយកសាងអាគារសិក្សា ២ ខ្នងមាន ២៥ បន្ទប់ នៅក្នុងបរិវេណ អនុវិទ្យាល័យទឹកល្អក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលមាន រាយនាមដូចខាងក្រោម ÷

១–លោក **ពៅ សិទ្ធិ** ឧបត្ថម្ភប្រាក់ ១០.០០០ ដុល្លារអាមេរិក

២–លោកស្រី **ស្នូរ សុខខេង** ឧបត្ថម្ភប្រាក់ ១០.០០០ ដុល្លារអាមេរិក

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រតិភូរាជរដ្ឋាភិបាល រាជធានីភ្នំពេញត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្តលេខានិងត្រា **ហត្ថលេខា និងត្រា**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៧៨ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់អភិបាល ខេត្តកណ្តាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិប្រគេន និងជូនចំពោះព្រះសង្ឃ និងសប្បុរសជនចំនួន ០៧ រូបដែលបានជួយកសាងសមិទ្ធផលដល់ស្រុកអង្គស្នួល ខេត្ត កណ្តាល មានអាគារសិក្សា និងជួសជុលផ្លូវលំក្នុងស្រុក ។ សប្បុរសជនទាំងនោះមានរាយនាមដូចខាងក្រោម ÷

ក-មេដាយស្ថាបនាជាតិ ថ្នាក់លេខ ១ :

១-លោក **ផាន គីមឆេង** ឧបត្ថម្ភប្រាក់ ១៣.០០០ ដុល្លារអាមេរិក

២-លោក **យូ ថេងចាន់** ឧបត្ថម្ភប្រាក់ ១៣.០០០ ដុល្លារអាមេរិក

៣-លោក **ង៉ូ សំអួន** ឧបត្ថម្ភប្រាក់ ១២.០០០ ដុល្លារអាមេរិក

ខ-មេដាយស្ថាបនាជាតិថ្នាក់ លេខ ២ ប្រគេនព្រះតេជគុណ **គង់ សុទ្ធិ** ចៅអធិការវត្តចំបក់ បរិច្ចាគបច្ច័យ ៨.០៤២ ដុល្លារអាមេរិក ។

គ-មេដាយស្ថាបនាជាតិថ្នាក់ លេខ ៣ ចំពោះ :

១-លោក **ខួច គឹមចាក់** ឧបត្ថម្ភប្រាក់ ៤.៦០០ ដុល្លារអាមេរិក

២-លោកស្រី **ម៉ុត ធាវ** ឧបត្ថម្ភប្រាក់ ១.៧៥០ ដុល្លារអាមេរិក

៣-លោក **ម៉ែន ញ៉ឹម** ឧបត្ថម្ភប្រាក់ ១.៣០០ ដុល្លារអាមេរិក

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខានិងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៤

អនុក្រឹត្យ លេខ ៧៩ អនក្រ.គត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់ រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិនិងប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ថ្នាក់លេខ ២ចំពោះលោក **ជុំ សារុន** អភិបាលស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលបានឧបត្ថម្ភប្រាក់ ៥.៣០០ ដុល្លារអាមេរិក ជួយកសាង សាលាបឋមសិក្សា ឃុំរលាំងកែន ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្ត កណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខានិងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៤

អនុក្រឹត្យ លេខ ៨០ អនក្រ.តត

ស្ដីពីលុបអនុក្រឹត្យលេខ ៣៦ អនក្រ និង អនុក្រឹត្យ លេខ ១០១ អនក្រ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : ត្រូវបានចាត់ទុកជានិរាករណ៍អនុក្រឹត្យលេខ ៣៦ អនក្រ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៤ ស្ដីពីការតែងតាំងលោក **គី បេងហាន** និងលុបឈ្មោះលោក **ឃុន ហាំង** លោក **ម៉ា ខុនឆ័យ** ចេញពីអនុក្រឹត្យតែងតាំងលេខ ១០១ អនក្រ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៤ ដោយមូលហេតុ អស់លោកដែលមានឈ្មោះក្នុងអនុក្រឹត្យខាងលើ ពុំបានចូលមកបំរើការងារ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ លោក **គី បេងហាន** លោក **ឃុន ហាំង** និង លោក **ម៉ា ខុនឆ័យ** ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយ ព្រះហស្ដលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ដលេខានិងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២-សេចក្ដីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៤

សេចក្ដីសំរេច លេខ ៤៧ សសរ្រ.គគ

ស្ដីពីការបង្កើតគណៈកម្មការចំរុះសំរាប់កិច្ច

សហប្រតិបត្តិការ កម្ពុជា—ហុងគ្រី

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព នៃ រាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមួយមានឈ្មោះថា : (គណៈកម្មការចំរុះសំរាប់កិច្ចសហប្រតិបត្តិការ **កម្ពុជា–ហុងគ្រី** ដែលមានសមាសភាពដូចតទៅ :

១–ឯកឧត្តម រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	ជាប្រធាន
២–ឯកឧត្តម រដ្ឋមន្ត្រីក្រសួងផែនការ	អនុប្រធាន
៣–តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៤–តំណាង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	សមាជិក
៥–តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	សមាជិក
៦–តំណាង ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល	សមាជិក
៧–តំណាង ក្រសួងពាណិជ្ជកម្ម	សមាជិក
៨–តំណាង ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ	សមាជិក
៩–តំណាង ក្រសួងអប់រំយុវជន និង កីឡា	សមាជិក
១០–មន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិអន្តរជាតិ	ជាលេខាធិការ

ប្រការ ២ : គណៈកម្មការចំរុះ កម្ពុជា–ហុងគ្រី មានភារកិច្ចដូចតទៅ :

–ជំនួយការអោយរាជរដ្ឋាភិបាល លើការងារសហប្រតិបត្តិការ កម្ពុជា–ហុងគ្រី

–សំរបសំរួលជាមួយស្ថាប័នដែលពាក់ព័ន្ធទៅនឹងកិច្ចសហប្រតិបត្តិការកម្ពុជា–ហុងគ្រី

-ពិភាក្សារៀបចំគំរោងការងារដែលមានលទ្ធភាពធ្វើសហប្រតិបត្តិការទៅតាមវិស័យនិមួយ ៗ

-ជំរុញនិងត្រួតពិនិត្យការអនុវត្តន៍ កិច្ចសហប្រតិបត្តិការប្រទេសទាំងពីរ

-ពិនិត្យសិក្សាផ្តល់មតិ និងលើកវិធានការលើរាល់ឯកសារពាក់ព័ន្ធដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និង សំរេច ។

-ធ្វើរបាយការណ៍ជូន រាជរដ្ឋាភិបាល តាមកាលកំណត់ ។

ប្រការ ៣ : គណៈកម្មការចំរុះកម្ពុជា-ហុងគ្រី មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ ឬ តំណាងក្រសួងស្ថាប័ននានា ដែលមានការពាក់ព័ន្ធទៅនឹងខ្លឹមសារ នៃការងារសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ដើម្បីចូលរួមបំពេញការងារ តាមការជាក់ស្តែង ។

ប្រការ ៤ : សមាជិកទាំងអស់ នៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំ និង ធ្វើការងារតាមសេចក្តីអញ្ជើញ និង ការណែនាំរបស់ប្រធាន ។

ប្រការ ៥ : គណៈកម្មការចំរុះកម្ពុជា-ហុងគ្រី មានសិទ្ធិប្រើប្រាស់ត្រាក្រសួងការបរទេស និង សហប្រតិបត្តិអន្តរជាតិ ជាផ្លូវការ ។

ប្រការ ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិអន្តរជាតិ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីឧស្សាហកម្ម រ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវ សហការអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

II- ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ ២៣៥ ប្រក.សហវ.ថ

ស្តីពីការបង្វែរឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥

- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្ដីពីការបែងចែកឥណទាន ផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្ដាក្រសួងតាមឥណទានចែងក្នុងច្បាប់ហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្ដីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ លេខ ១៩៨ សណ.ផក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិកា របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ នូវការបង្វែរឥណទាន ដូចបានបញ្ជាក់ខាងក្រោមនេះ ÷

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានដើមឆ្នាំ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
១១	០២	០២	០៣	ការបង្វែរពីជំពូក ១១ សោហ៊ុយស្នាក់នៅ	៦.៥០០	–	៦.០០០ ៦.០០០	៥០០
១១	០២	០២	០២	ផលប្រយោជន៍ជំពូក១១ សោហ៊ុយបេសកកម្ម	៦៣.២៦០	៦.០០០ ៦.០០០	–	៦៩.២៦០

ប្រការ ១ : ឯកឧត្ដមរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជាអ្នកទទួលបន្ទុកក្នុងការអនុវត្តន៍ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឆាយ ថន

* * *

២-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ ៤៦១ សសរ.សក.ប

ឧបនាយករដ្ឋមន្ត្រី--រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១-១០-១៩៩៤ ស្តីពី ការកែសម្រួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញប្រកាស លេខ ២៧៨៥ ប្រក.សក.ប ចុះថ្ងៃទី ៣០-៩-១៩៩៤ របស់ក្រសួង សាធារណការ និងដឹកជញ្ជូន ស្តីពីការបែងចែកភារកិច្ចជូនឯកឧត្តម **នូ សាំងខន** អនុរដ្ឋ លេខាធិការទទួលបន្ទុកការងារដឹកជញ្ជូន
- បានឃើញប្រកាសលេខ ២៧៨៦ ប្រក.សក.ប ចុះថ្ងៃទី ៣០-៩-១៩៩៤ របស់ក្រសួង សាធារណការ និងដឹកជញ្ជូន ស្តីពីការបែងចែកភារកិច្ចជូនឯកឧត្តម **ជិន គីមស្រេង** អនុរដ្ឋលេខាធិការទទួលបន្ទុកការងារសំណង់ធំ ៗ
- យោងតាមកិច្ចការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : ឯកឧត្តម **ជិន គីមស្រេង** អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និង ដឹកជញ្ជូន ដែលបច្ចុប្បន្នទទួលបន្ទុកគ្រប់គ្រង លើវិស័យការងារធំ ៗ សំណង់ធំ ៗ ត្រូវចាត់តាំង ជាបណ្តោះអាសន្ន អោយគ្រប់គ្រងលើវិស័យ ការងារដឹកជញ្ជូនផ្លូវគោក ផ្លូវទឹកជា

បន្ថែមជំនួយឯកឧត្តម នូ សារ៉ ... ដែលត្រូវទៅ ...ពការមុខងារផ្សេងទៀត ទំរាំមានការតែងតាំងជាថ្មី ។

ក្នុងករណីណាដែលភារកិច្ចខាងលើ មានការទាក់ទងចំបងទៅលើនយោបាយជាក់ស្តែងរបស់ រាជរដ្ឋាភិបាល សាមីខ្លួនត្រូវមានការពិគ្រោះជាមួយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី–រដ្ឋមន្ត្រីក្រសួង សាធារណការ និង ដឹកជញ្ជូនជាមុនសិនមុននឹងធ្វើការសំរេច ។

ប្រការ ២ : លោកអគ្គនាយក នាយកខុទ្ទកាល័យ ត្រូវទទួលបន្ទុកអនុវត្តរៀង ៗ ខ្លួន តាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃដែលបានចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ហត្ថលេខា និងត្រា

អ៊ឹង គៀត

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ ៤៦២ សសរ.សក.ប

ឧបនាយករដ្ឋមន្ត្រី–រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

* * *

– បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១–១០–១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា

– យោងតាម កិច្ចការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការបច្ចេកទេសមួយជាជំនួយការគណៈកម្មការកណ្តាល សាងសង់ព្រះសក្យមុនីចេតីយ៍ដែលមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្តម	**ជីន គីមស្រេង**	អនុរដ្ឋលេខាធិការ	ប្រធាន
២-លោក	**តាន់ ហៃសឿន**	នាយកនាយកដ្ឋានស្ថានថ្នល់	អនុប្រធាន
៣-លោក	**ហែម យីមអេង**	នាយកនាយកដ្ឋាននគរោបនីយកម្ម	សមាជិក
៤-លោក	**យីត ម៉ុណ្ណា**	នាយកមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស	សមាជិក
៥-លោក	**រស់ ម៉ុរ៉ាត់**	ស្ថាបត្យករ	សមាជិក
៦-លោក	**មា ខូន័យ**	ស្ថាបត្យករ	សមាជិក
៧-លោក	**ម៉ុង ម៉ិនហួន**	វិស្វករ	សមាជិក
៨-លោក	**ហ៊ុយ ណារ៉ា**	វិស្វករ	សមាជិក
៩-លោក	**ផូ សុគា**	មន្ត្រីអគ្គនាយកដ្ឋានសំណង់	លេខាធិការ

ប្រការ ២ : គណកម្មការបច្ចេកទេស មានភារកិច្ចជាជំនួយការអោយគណកម្មការកណ្តាល សាងសង់ព្រះសក្យមុនីចេតីយ៍ ក្នុងការសិក្សាស្រាវជ្រាវ ត្រួតពិនិត្យលើផ្នែកបច្ចេកទេស ជានាបាននូវ គុណភាព ដើម្បីអោយសំរេចបានលទ្ធផលល្អប្រសើរ សមស្របតាមព្រះរាជតម្រិះរបស់ព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង ។

ប្រការ ៣ : សមាជិកគណកម្មការបច្ចេកទេសនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រការ ៤ : លោកអគ្គនាយក លោកនាយកខុទ្ទកាល័យ ត្រូវទទួលបន្ទុកអនុវត្តរៀង ៗ ខ្លួន តាមខ្លឹមសារ នៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ហត្ថលេខា និងត្រា

អ៊ឹង គឿត

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្ដីសំរេច លេខ ៤៦៣ សសរ.សក.ប

ស្ដីពីការតែងតាំងមន្ត្រី-រាជការ

* * *

ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពី ការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១-១០-១៩៩៤ ស្ដីពី ការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- យោងតាម កិច្ចការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : ឯកឧត្ដម **ឃី តាំងលីម** ត្រូវបានតែងតាំងជាទីប្រឹក្សាជំនួយការ អមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ទទួលភារកិច្ចការងារនៅគណៈកម្មការជាតិ ទន្លេមេគង្គ ។

ប្រការ ២ : លោកអគ្គនាយក លោកនាយកខុទ្ទកាល័យ ត្រូវទទួលបន្ទុកអនុវត្តរៀង ៗ ខ្លួន តាមខ្លឹមសារ នៃសេចក្ដីសំរេចនេះ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ហត្ថលេខា និងត្រា

អ៊ឹង គៀត

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ ៤៦៤ ប្រក.សក.ប

ស្តីពីការបញ្ចូលមន្ត្រីរាជការក្នុងក្របខ័ណ្ឌ ក្រសួងសាធារណការ និងដឹកជញ្ជូន

* * *

ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១-១០-១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញលិខិតលេខ ៨៩៣ សជណ.ផក ចុះថ្ងៃទី ៣០-៥-៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការឯកភាពអោយក្រសួងសាធារណការ និង ដឹកជញ្ជូន ជ្រើសរើសលេខាធិការកុំព្យូទ័រ ០១ រូប
- បានឃើញលិខិតលេខ ៤០៥ មស.ក្រខ ចុះថ្ងៃទី ០៩-១០-៩៣ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

សំរេច

ប្រការ ១ : កញ្ញា **ឌុត លាង ម៉ាន់នី** ជំនាញខាងគណនេយ្យ និង កុំព្យូទ័រ ត្រូវបានជ្រើសរើសបញ្ចូលក្នុងក្របខ័ណ្ឌ ក្រសួងសាធារណការ និងដឹកជញ្ជូន ចាប់ពីថ្ងៃទី ខែ មករា ឆ្នាំ ១៩៩៤ តទៅ ដោយចាត់អោយទទួលភារកិច្ចជាលេខាធិការកុំព្យូទ័ររបស់ឯកឧត្តម ឧបនាយក រដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន ។

ប្រការ ២ : លោកអគ្គនាយក លោកនាយកខុទ្ទកាល័យ ត្រូវទទួលបន្ទុកអនុវត្តរៀង ៗ ខ្លួន តាមខ្លឹមសារ នៃប្រកាសនេះ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ហត្ថលេខា និងត្រា

អ៊ុង គៀត

* * *

ក-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពតិមាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១០៤/៩៥ ព.ម.ប្រក

ស្តីពីការបង្កើតអនុគណៈកម្មការទទួល

សម្ភារៈ ទូរទស្សន៍

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- ពិនិត្យលើតម្រូវការមានលក្ខណៈចាំបាច់ ។

សំរេច

ប្រការ ១ : បង្កើតអនុគណៈកម្មការមួយ ដើម្បីទទួលសម្ភារៈ និង ប្រគល់សម្ភារៈសំរាប់អគ្គនាយកដ្ឋានទូរទស្សន៍ ដែលមានសមាសភាពដូចខាងក្រោម ÷

- លោក **ហ៊ឹម សួន** ជាប្រធាន
- លោក **ញ៉ើន សម្បត្តិ** ជាអនុប្រធាន

- លោក ឃឹម គីមស៊ុន សមាជិក
- លោក អ៊ុយ ឆួន សមាជិក
- លោក ឈឿន ឈរារិទ្ធ សមាជិក
- លោក ហែម វណ្ណរិទ្ធ សមាជិក

ប្រការ ២ : អនុគណៈកម្មការនេះ មានភារកិច្ច :

- បែងចែកភារកិច្ចទទួលខុសត្រូវតាមការពិភាក្សា និងសំរេច
- ពិនិត្យអោយបានត្រឹមត្រូវរវាងសំភារៈក្នុងបញ្ជី និងសំភារៈជាក់ស្តែងដែលត្រូវប្រគល់
- ធ្វើរបាយការណ៍ ឬ សេចក្តីរាយការណ៍ពិស្តារជូនគណៈកម្មការដើម្បីគណៈកម្មការ រាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង ។

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានទូរទស្សន៍កម្ពុជា និង សាមីខ្លួន មានភារៈអនុវត្តតាមប្រកាស អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៤៥/៩៥ ពម

* * *

ស្តីពីការអនុញ្ញាតអោយលោក ម៉មសុណង់ដូ បើកស្ថានីយ៍ផ្សាយសំលេង FM លេខរលកអាកាស ១០៥

រដ្ឋមន្ត្រី ក្រសួង ពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ។

- ពិនិត្យលើសំណើសុំច្បាប់អនុញ្ញាតតម្លើងបើកស្ថានីយ៍វិទ្យុ FM មួយនៅទីក្រុងភ្នំពេញ សំរាប់សមាគមកម្ពុជា ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ម សុវណ្ណច័ន្ទ** ប្រធានសមាគមកម្ពុជាដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច បើកស្ថានីយ៍វិទ្យុផ្សាយសម្លេង FM រលកអាកាស ១០៥ ដែលមានកំលាំងតិចជាង ឬ អតិបរមា ១០គីឡូវ៉ាត់ ហើយដែលមានទីតាំងស្ថិតនៅ សណ្ឋាគារឆាណាថោន ផ្លូវសម្តេចប៉ាន សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការផ្សព្វផ្សាយរបស់ស្ថានីយ៍វិទ្យុផ្សាយសម្លេង FM នេះត្រូវគោរព និងអនុវត្តតាមកិច្ចសន្យារបស់ខ្លួនដែលបានតម្កល់ទុកនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីមិនគោរពកិច្ចសន្យា សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និងសោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ មន្ទីរពត៌មានរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៤៦/៩៥ ពម.ប្រក

ស្តីពីការអនុញ្ញាតអោយលោក តាំង ឃាង បើកអាជីវកម្មរោងពុម្ព

ឈ្មោះ « ហេងហេង »

រដ្ឋមន្ត្រី ក្រសួង ពត៌មាន

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- យោងលិខិតជូនដំណឹងរបស់ក្រសួងពត៌មានលេខ ១២២៤-៩៤. ពម, ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ ។
- យោងលិខិតអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ពឈ្មោះ « ហេង - ហេង » របស់លោក **តាំង - ឃាង** ចុះថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **តាំង - ឃាង** ស្ថិតនៅផ្ទះលេខ ២១៨ អឺ១ ផ្លូវ ១០៧ សង្កាត់អូរឫស្សី ៤ ខ័ណ្ឌ ៧ មករា ក្រុងភ្នំពេញ បើកអាជីវកម្មរោងពុម្ព ដែលមានឈ្មោះ «ហេង - ហេង » ស្ថិតនៅផ្ទះលេខ ៦៧ អឺ០ ផ្លូវ ១៤១ សង្កាត់បឹងព្រលឹត ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមខសន្យា សមស្របទៅនឹងទំនៀមទំលាប់ និងសន្តិសុខសណ្តាប់ធ្នាប់សង្គម និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស ដូចមានចែងក្នុងប្រការ២ សាមីខ្លួននឹងត្រូវទទួលទោស តាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និង ប្រធានមន្ទីរ ពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

៤-ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១២៣ ប្រក.វវស.បុ

ស្តី ពី

ការផ្អាកការងារមួយរយៈដោយពុំទទួលបៀវត្ស

* * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- យោងសារាចរណែនាំលេខ ០៣ សរ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៣ ស្តីពីការអនុញ្ញាតអោយមន្ត្រីរាជការ ស៊ីវិលផ្អាកការងារមួយរយៈដោយគ្មានបៀវត្សប្រចាំខែ ។
- យោងតាមសំណើសុំរបស់លោក **កែវ ម៉ុន្នី** បុគ្គលិកនៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តបាត់ដំបង ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ១៩៩៥ ។
- យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួងចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៩៥

សំរេច

មាត្រា ១ : ត្រូវបានអនុញ្ញាតអោយឈប់សំរាកផ្អាកការងារចំនួន ០១ ឆ្នាំ ដល់លោក **កែវ ម៉ុន្នី** បុគ្គលិក នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តបាត់ដំបង ដោយគ្មានបៀវត្ស និងស្នើសុំរក្សាទុក ក្របខ័ណ្ឌដដែលដោយគិតចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៥ ដល់ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៦ ។

មាត្រា ២ : បៀវត្សប្រចាំខែ និង រាល់ផលប្រយោជន៍របស់លោក **កែវ ម៉ុន្នី** ត្រូវផ្អាកលែងអោយបើកចាប់ពី ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៥ តទៅរហូតដល់មានលិខិតអនុញ្ញាតអោយចូលបំរើការងារពីក្រសួងវិញ ។

មាត្រា ៣ : នាយកដ្ឋានបុគ្គលិក និង កិច្ចការសង្គម នាយកដ្ឋានផែនការ គណនេយ្យ និង ហិរញ្ញវត្ថុ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តបាត់ដំបង ព្រមទាំងលោក **កែវ ម៉ុន្នី** ត្រូវអនុវត្តនូវប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

នុត ណារ៉ាង

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១២៤ ប្រក.វបស.បុ

ស្តីពី

ការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការ

មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកំពង់ធំ

* * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ករុណាព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- យោងតាមលិខិតសុំផ្លាស់ប្តូរកន្លែងធ្វើការ របស់អ្នកស្រី **ស៊ុំ វណ្ណនី** ពីមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកំពង់ធំ ទៅបំរើការងារនៅនាយកដ្ឋានសិល្បៈ និង ទស្សនីយភាព ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៥ ។
- យោងតាមចំណាំយល់ព្រមពីថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ១៦.៦.៩៥ ។

សំរេច

មាត្រា ១ : អ្នកស្រី **ស៊ុន ចន្ថន្នី** បុគ្គលិកការិយាល័យសិល្បៈផ្នែករបាំ នៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកំពង់ធំត្រូវបាន អនុញ្ញាតអោយផ្លាស់ទៅបំរើការងារនៅនាយកដ្ឋាន សិល្បៈ និង ទស្សនីយភាព ។

មាត្រា ២ : មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តកំពង់ធំ ត្រូវផ្ទេរប្រាក់បៀវត្សរបបឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន និងក្រុបខ័ណ្ឌមួយកន្លែងជូននាយកដ្ឋានសិល្បៈ និង ទស្សនីយភាព ។

មាត្រា ៣ : នាយដ្ឋានបុគ្គលិក និង កិច្ចការសង្គម នាយកដ្ឋានផែនការគណនេយ្យ និង ហិរញ្ញវត្ថុ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកំពង់ធំ ព្រមទាំងអ្នកស្រី **ស៊ុន ចន្ថន្នី** មាន ភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

នុត ណារ៉ាង

* * *

៥-នីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ៣៤៧ ប្រក.កសក.ចត

ស្តីពីការតែងតាំងតម្លើងឋានៈមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស /រកត /១០៩៤ / ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម ។
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៣ ស្តីពីការដាក់អគ្គនាយកដ្ឋានចំការកៅស៊ូ អោយស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។
- តាមសំណើលេខ ២៨៨ អត.ចត ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៥ របស់អគ្គនាយកដ្ឋានចំការកៅស៊ូ លេខ ០១៣ នក្ស.រក ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៤ របស់នាយកដ្ឋាន ក្សេត្រសាស្ត្រ ។

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងតំលើងឋានៈមន្ត្រីរាជការដូចមានរាយនាមខាងក្រោម ជាអនុប្រធានការិយាល័យនៅអគ្គនាយកដ្ឋានចំការកៅស៊ូ និង នាយកដ្ឋានក្សេត្រសាស្ត្រដូចតទៅ ÷

ក / <u>អគ្គនាយកដ្ឋានចំការកៅស៊ូ</u> :

១ / លោក **ឡាយ សារ៉េត** បច្ចុប្បន្នប្រធានផ្នែកពិធីការមន្ទីរ នៃអគ្គនាយកដ្ឋានចំការកៅស៊ូ តែងតាំងតំលើងឋានៈជា អនុប្រធានការិយាល័យរដ្ឋបាលមន្ទីរ នៃអគ្គនាយកដ្ឋានចំការកៅស៊ូ ។

ខ/<u>នាយកដ្ឋានក្សេត្រសាស្ត្រ</u> :

១–លោក **ឌុច សារ៉ាវុធ** បច្ចុប្បន្នប្រធានមណ្ឌលអភិវឌ្ឍន៍កសិកម្មតាស្លាង តែងតាំងតំលើងឋានៈជាអនុប្រធាន ការិយាល័យផែនការ គណនេយ្យ នាយកដ្ឋានក្សេត្រសាស្ត្រ ។

មាត្រា ២ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាន អគ្គនាយកដ្ឋានចំការកៅស៊ូ ប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ និង សាមីជន ត្រូវទទួល បន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួនចាប់ពីថ្ងៃដែលបាន ចុះហត្ថលេខា នេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

តាវ សេងហួរ

* * *

៦-នីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាស លេខ ៤៦៧ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **ផាន់ ខ្មៀម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៥៨៨០៣ ត.ក ចុះថ្ងៃទី ១១-៦-៨៦ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិកណ្ដោល ឃុំពត់សរ ស្រុក បាទី ខេត្តតាកែវ បើកដំណើរការ ផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ២៤ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : លោក **ផាន់ ខ្មៀម** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំង ដែល បានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវ ធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើស ច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញដោយ គ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៤៦៨ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១: អនុញ្ញាតអោយអ្នកស្រី **សុខ ហ៊ួន** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦១៧៧២ ត.ក ចុះថ្ងៃទី ២៤-៦-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ២ ឃ្លាំងសម្បត្តិ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក អ្នកស្រី **សុខ ហ៊ួន** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៤៦៩ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **សួន ហឿង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៤១០១៦ ក.ណ ចុះថ្ងៃទី ២៣-០២-៨៩ អាស័យបច្ចុប្បន្នភូមិសៀមរាប ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **សួន ហឿង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបាន យ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មាន សំណងឡើយ ។

* * *

ប្រកាស លេខ ៤៧០ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ រោងម៉ាស៊ីនកិនស្រូវដែលមានអ្នកស្រី **គឹម សាន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជាកាន់អត្តសញ្ញាណប័ណ្ណលេខ ០៦១១១៦ ព.ស ចុះថ្ងៃទី ១៩-១០-៨៨ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ២ ភូមិ ត្រពាំងផង ឃុំត្រពាំងផង ស្រុក បាកាន ខេត្តពោធិសាត់ បើកដំណើរការ ផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ៨០ សេះ នៅក្នុងទីតាំង ក្រុមទី ១ ភូមិដូងជ្រុំ បឹងបត់កណ្តាល ស្រុក បាកាន ខេត្ត ពោធិសាត់ ។

ប្រការ ២ : អ្នកស្រី **គឹម សាន** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែល បានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិច បំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវ ធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើស ច្បាប់ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញដោយ គ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៤៨១ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ សហគ្រាសផលិតគ្រឿងបង្អែមរីម«**តូនី** »ដែលមានលោក **សុខ ហាច** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២៣២២១៣ ភ.ព ចុះថ្ងៃទី ២០-៧-៩១ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៥ អឺ១ ផ្លូវលេខ ១៤០ ក្រុមទី ៦២ សង្កាត់ មនោរម្យ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បើកដំណើរការ ផលិតកម្ម នៅក្នុងទីតាំង ក្រុមទី ១ ភូមិ ត្រពាំងពោធិ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **សុខ ហាច** ត្រូវរៀបចំសហគ្រាសរបស់ខ្លួនអោយរួចស្រេចជាស្ថាពរ ក្នុងរយៈ ពេល ០៦ ខែ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។

ប្រការ ៣ : ក្នុងកិច្ចដំណើរផលិតកម្ម ម្ចាស់សហគ្រាសត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិដ្ឋាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និង បទបញ្ញត្តិដែលមានជាធរមាន ។

ប្រការ ៤ : សហគ្រាសនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្ត : ឈើស៊ុមទ្វារ សន្ទឹកទ្វារ ក្ដារបន្ទះ ក្ដារ ការ៉ូ ក្ដារប៉ាឡែត តុ ទូ កៅអី គ្រែ ក្ដារម្ស៉ល ទ្រុងរថយន្ត និង ឈើក្រឡឹង ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺឈើដែលមានលក្ខណៈស្របច្បាប់ដែលសាមី សហគ្រាសត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៥ : ម្ចាស់សហគ្រាសត្រូវជូនដំណឹងមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ អំពីកាលបរិច្ឆេទ នៃការចាប់ផ្ដើមដំណើរការជាផ្លូវការ និង ធ្វើរបាយការណ៍ប្រចាំ ខែអំពីសកម្មភាពផលិតកម្មរបស់សហគ្រាស ។

ប្រការ ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៤៨៦ ឧក.ប្រក ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយរោងឧស្សាហកម្មផលិតគ្រឿងសង្ហារឹម «**ឫទ្ធិម៉ិចកូ** RITTHY MEXCO» ដែលមានលោក **ឡោង ឫទ្ធិ** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៦២៣៨៩ភ.ព ចុះថ្ងៃទី ១៥–៩–៨៩ ជាប្រធានអាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៩៨ ផ្លូវលេខ ៣១០ និង ៦៣ សង្កាត់បឹងកេងកង ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បើកដំណើរការផលិតកម្ម នៅក្នុងទីតាំង ផ្លូវលេខ ១៣ ឃុំ ២ ធ្នូ ស្រុកស្អួល ខេត្តក្រចេះ ។

ប្រការ ២ : លោក **ឡោង ឫទ្ធិ** ត្រូវរៀបចំរោងឧស្សាហកម្មរបស់ខ្លួនអោយស្រេចជាស្ថាពរ ក្នុងរយៈពេល ០៤ ខែ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសកាលកំណត់ប្រកាសនេះ ត្រូវចាត់ទុកជាមោឃៈ ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងឧស្សាហកម្មត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិដ្ឋាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និងបទបញ្ញត្តិ ដែលមានជាធរមាន ។

ប្រការ ៤ : រោងឧស្សាហកម្មនេះត្រូវបានអនុញ្ញាតអោយផលិត នូវមុខផលិតផលជាសាវនុ្ត: តុ កៅអី គ្រប់ ប្រភេទ សាឡុង ប៉ាខ្សែត គ្រោងទ្វារ-បង្អួច ក្តារម្ហូស និង កំណល់ ផ្លូវដែក ។ វត្ថុធាតុដើម ដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺឈើដែលមាន លក្ខណៈ ស្របច្បាប់ដែលសាមី រោងឧស្សាហកម្ម ត្រូវរ៉ាប់រងដោះស្រាយដោយ ខ្លួនឯង ។

ប្រការ ៥ : ម្ចាស់រោងឧស្សាហកម្មត្រូវជូនដំណឹងមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តក្រចេះ អំពីកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការជាផ្លូវការ និងធ្វើ របាយការណ៍ប្រចាំ ខែអំពីសកម្មភាពផលិតកម្មរបស់រោងឧស្សាហកម្ម ។

ប្រការ ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវ ធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើស ច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញដោយ គ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៥៤៦ រៀល